BMI00141

# សម្ភាសន៍ជាមួយឈ្មោះ តូច សុទី ភេទប្រុស អាយុ៩៦ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ “កងចល័តនៅត្រពាំងថ្ម”
# សព្វថ្ងៃរស់នៅភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ហ៊ិន សុធានី
# ០០:៣៦:៣០
# ១៩ទំព័រ

ធានី : ថ្ងៃនឹង ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ។ ខ្ញុំឈ្មោះ ធានី មកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចុះមកនេះចង់សាកសួរពីប្រវត្តិលោកពូ ដែលបានឆ្លងកាត់ពីសម័យខ្មែរក្រហម ។ ហើយប្រវត្តិរឿងរ៉ាវទាំងអស់នេះ ពួកខ្ញុំសុំយកមកចងក្រងសរសេរជាទស្សនាវដ្ដី ក៏ដូចជាទុកឲ្យក្មេងៗឬអ្នកស្រាវជ្រាវផ្សេងៗ មកស្រាវជ្រាវទុកឲ្យក្មេងក្រោយបានរៀនបានសូត្រចឹង ។ ខ្ញុំអនុញ្ញាតិសុំថតជាសម្លេងក៏ដូចជាថតជារូបបានទេ?

សុទី : បាន ។

ធានី : លោកពូមានឈ្មោះអីដែរ?

សុទី : តូច សុទី ។

ធានី : ឆ្នាំនឹងអាយុប៉ុន្មាន?

សុទី : អាយុ៩៦ ។

ធានី : ពូមានស្រុកកំណើតនៅណាដែរ?

សុទី : នៅភូមិដើមវត្ត ។

ធានី : ចឹងសព្វថ្ងៃពូរស់នៅណាដែរ?

សុទី : នៅភូមិនឹងដដែល ភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

ធានី : ឪពុកពូមានឈ្មោះអីដែរ?

សុទី : តូច ហាក់ ។

ធានី : គាត់នៅរស់?

សុទី ៖ ស្លាប់ ។

ធានី ៖ គាត់ស្លាប់ពីអន្កាល់?

សុទី ៖ ស្លាប់ឆ្នាំ៩៣ ។

ធានី ៖ ដោយសារអីដែរ?

សុទី ៖ ជម្ងឺចាស់ជរា ។

ធានី ៖ ចុះម្ដាយពូ?

សុទី ៖ ម្ដាយ ឈឿ សៀក ។

ធានី ៖ គាត់នៅរស់ទេ?

សុទី ៖ នៅរស់ ។

ធានី ៖ នៅជាមួយពូ?

សុទី ៖ នោះនៅផ្ទះប្អូន ។

ធានី ៖ ពូមានបងប្អូនប៉ុន្មាននាក់?

សុទី ៖ ៤ ។

ធានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុទី ៖ ប្រុស២ ស្រី២ ។

ធានី ៖ គាត់នៅរស់ទាំងអស់?

សុទី ៖ បាទ!

ធានី ៖ ពូរៀបគ្រួសារនៅឆ្នាំណាដែរ?

សុទី ៖ ឆ្នាំ៨៣ ។

ធានី ៖ គ្រួសារពូឈ្មោះអីគេ?

សុទី ៖ នួន ភួង ។

ធានី ៖ មានកូនប៉ុន្មាននាក់?

សុទី ៖ កូន២នាក់ ។

ធានី ៖ ស្រី?

សុទី ៖ ស្រី១ ប្រុស១ ។

ធានី ៖ ពូរៀនសូត្រដល់ណាដែល កាលពីនៅក្មេងៗ?

សុទី ៖ ក្មេងរៀននៅបឋមសិក្សាព្រះនេត្រព្រះ ។

ធានី ៖ រៀនបានត្រឹមបឋម?

សុទី ៖ រៀនដល់វិទ្យាល័យសម្តេចឪ នៅស្វាយ ។

ធានី ៖ ចឹងពូរៀនចប់ថ្នាក់?

សុទី ៖ រៀនចប់ ។

ធានី ៖ រៀនបានបាក់ឌុប?

សុទី ៖ អត់បានប្រឡងផង ចប់ឆ្នាំដែលប្រឡង ។

ធានី ៖ កាលសម័យមុនថ្នាក់ទី១?

សុទី ៖ ថ្នាក់ទី១ ។

ធានី ៖ វិទ្យាល័យស្វាយ?

សុទី ៖ បាទ! វិទ្យាល័យសម្តេចឪ ។

ធានី ៖ បន្ទាប់មកទៀតម៉េចពូៗ អាចរៀបរាប់រឿងរ៉ាវពូតាំងពីក្មេង រហូតមកដល់សម័យ៣ឆ្នាំ រហូតមកដល់សម័យឥឡូវ?

សុទី ៖ គ្មានអីទេ តាំងពីចូលរៀននៅសាលាបឋមសិក្សានៅនេះ ចប់នេះទៅស្វាយ ។

ធានី ៖ រៀនរហូត?

សុទី ៖ រៀនរហូត អត់មានបានធ្វើអីទេ ដល់សម័យ៧៥មក ក៏នៅចល័តនៅអាងត្រពាំងថ្ម វែកដី ធ្វើអាង ។

ធានី ៖ ចឹងនៅឆ្នាំ៧៥ ពូធ្វើចល័តនៅអាងត្រពាំងថ្មម៉ង?

សុទី ៖ បាទ! គេហៅទៅចល័តនៅអាងត្រពាំងថ្ម ចេញពីរៀន ។

ធានី ៖ ចឹងពូថានៅពេលដែលរៀនចប់ថ្នាក់នឹង នៅឆ្នាំ៧៥ដែរ?

សុទី ៖ ៧៥ ។

ធានី ៖ ពីថាត្រៀមប្រឡង?

សុទី ៖ ហ្នឹង ។

ធានី ៖ អត់បានប្រឡងទេ?

សុទី ៖ អត់បានៗ ។

ធានី ៖ ពេលនោះយ៉ាងម៉េចខ្លះបានអត់បានប្រឡង?

សុទី ៖ ចុះគេចូលខ្មែរក្រហមវ៉ៃបានអស់ហើយ ១៧ មេសា អត់បានប្រឡង ។

ធានី ៖ ហើយដល់ពេលនឹង ពូនៅនឹងរហូត ឬក៏យ៉ាងម៉េចនៅស្វាយនឹង?

សុទី ៖ ទេ! គេដាច់ចេញ ជម្លៀសចេញស្វាយ ដេញប្រជាជនទាំងអស់មកស្រុកកំណើតវិញ ។

ធានី ៖ កាលនឹងគេប្រាប់ថាម៉េចបានគេឲ្យជម្លៀសប្រជាជនចេញពីស្វាយទាំងអស់?

សុទី ៖ អានឹងគេ ប្រាប់ថាម៉េច គេនេះបណ្ដោយ គេថាគេនឹងរៀបចំ គេជម្លៀសចេញឲ្យអស់ទៅ អង្គការអាវខ្មៅនឹងរៀបចំ ។

ធានី ៖ គេនិយាយចឹង?

សុទី ៖ ហ្នឹងហើយរៀបចំថ្មី ។

ធានី ៖ ពេលនឹងពូយល់ថាម៉េចដែរ ចិត្តពូអីរៀនសូត្រត្រូវប្រឡងផង?

សុទី ៖ កាលសម័យកាលនោះ គ្រូ សិស្សនេះគេចូល ប្រធានសិស្សគេនោះក៏ចូលជុំពួកអាវខ្មៅ កាលនោះ ។

ធានី ៖ មានអ្នកចូលទៅខាងផ្នែកនឹងដែរ?

សុទី ៖ នោះហើយមានតើ ។

ធានី ៖ គេប្រាប់ថាម៉េច?

សុទី ៖ គេថាទេ! មិនមានប្រាប់អី គេថាឲ្យរៀបខោអាវចេញមកស្រុកកំណើតរៀងៗខ្លួនទៅ ។

ធានី ៖ ហើយពូស្គាល់ឈ្មោះគាត់ទេ អ្នកប្រជុំហោ?

សុទី ៖ ឈ្មោះអី ឈ្មោះ យើយ ប៉ុនឆាប់បាត់ហើយឈ្មោះហ្នឹង ។

ធានី ៖ យើយ គាត់ធ្វើការខាងអី?

សុទី ៖ កាលនោះគេ មិនដឹងថាគេធ្វើអីទេ ដែលខ្ញុំនៅវែកដីនេះមកអាងត្រពាំងថ្ម មកជួបគេៗឲ្យត្រី ងៀត គេឲ្យខោអាវស្លៀកពាក់ ខោអាវខ្មៅ ។

ធានី ៖ អត់ដឹងគាត់មានមុខងាររអី?

សុទី ៖ អត់ដឹងទេ មិនហ៊ានសួរគេផង ។

ធានី ៖ បានគេឲ្យ?

សុទី ៖ អឺ!

ធានី ៖ ហើយចឹងគេដឹងពូអ្នករៀន អ្នកសូត្រ?

សុទី ៖ ហ៎! ដឹងរៀនថ្នាក់ជុំគ្នា រៀនម៉ាស្រែករគ្នានឹង តែដល់សម័យលន់ នល់ គេប្រធានសិស្សម៉ា សាលាសម្ដេចឪ ។ ដល់ក្រោយមក មិនដឹងថាគេធ្វើអី សម្រាប់ដល់ខ្ញុំទៅនៅចល័តនៅនឹង ឃើញគេ ដឹកអង្ករដឹកត្រីងៀតទៅជួបទៅ គេលួចឲ្យត្រីងៀត ។

ធានី ៖ គាត់អ្នកដឹកអង្ករ ដឹកត្រីងៀតទេ?

សុទី ៖ ហ្នឹងហើយ ។

ធានី ៖ ចឹងកាលពេលពូជម្លៀសមកនេះ មានប្រជាជនអ្នកនៅស្រាយ អត់មានអ្នកថ្មីមកពីណាពីណៃ?

សុទី ៖ អត់ទាន់មានទេ មានតែអ្នកនៅស្រាយសម័យដែលគេជម្លៀសចេញ ។

ធានី ៖ ហើយដល់ពេលពូមកដល់ភូមិបានមានអ្នកថ្មីមកដែរ ។

សុទី ៖ បាទ! ដល់ក្រោយមក បានឃើញអ្នកថ្មីមកនៅតាមភូមិ ។

ធានី ៖ យ៉ាងម៉េចទៅពូ គាត់មកពីណាខ្លះ?

សុទី ៖ អូ! មិនដឹងដែរ មិនដឹងថាមកពីណា ថាមកពីភ្នំពេញៗ ខ្ញុំនៅតែនោះទៅនៅចល័ត គេហៅពួកស្អី គេហៅប្រជាជនថ្មីៗ ។

ធានី ៖ តែកាលនឹងពូបានរត់មកនៅស្រុកយើងទេ ក៏ទៅចល័តរហូត?

សុទី ៖ ខ្ញុំរត់មកដល់ភូមិក៏ខាងភូមិគេត្រូវការចល័ត ក៏ខ្ញុំនៅក្មេងគេឲ្យទៅចល័តទៅបណ្ដោយ ។

ធានី ៖ ចឹងកាលនឹងពូមកដល់ភូមិបានប៉ុន្មានថ្ងៃ បានឲ្យទៅចល័ត?

សុទី ៖ មកនៅបានប្រហែលមកនៅធ្វើស្រែនឹងរួច ។

ធានី ៖ ធ្វើស្រែអីគេ?

សុទី ៖ ធ្វើស្រែរដូវវស្សានេះរួចក៏ ។

ធានី ៖ បានគេឲ្យទៅចល័ត?

សុទី ៖ បាទ! ទៅ ។

ធានី ៖ ចឹងចល័តនឹង កាលពេលពូទៅខែ៥-៦?

សុទី ៖ ទៅមុនដំបូងខែវស្សា មុនដំបូងធ្វើតាមផ្លូវជាតិ តាមព្រៃមាន់បត់ទំនប់ដេញៗទៅ បានទៅដល់អាងត្រពាំងថ្ម ។

ធានី ៖ ដល់អាងនឹងឃើញម៉េចខ្លះ មានអីខ្លះ?

សុទី ៖ អឺ! គ្មានដើរទៅណារួច នៅតែអន្ទង់ដឹកដី មានគេឲ្យយើងដើរទៅណា ទាំងយប់ទាំងថ្ងៃ ។

ធានី ៖ តែពេលពូទៅដល់ឃើញអាងនឹង មានអាងហើយ?

សុទី ៖ នៅអត់ទាន់មាន ទាន់មានអីទេ គ្រាន់តែមានផ្លូវគេចាស់ ផ្លូវបូរាណ ដូចថាគេថាអាងស្ពានរាបមុនដំបូង ឃើញថ្មស្ពានរាប ។

ធានី ៖ មានផ្លូវចាស់ គេហៅស្ពានរាប?

សុទី :	ហ្នឹងហើយ ។

ធានី :	មានស្ពានមានអីដែរ?

សុទី :	ស្ពានអាថ្មបូរាណ ថ្មបាយក្រៀមយើង ដល់យើងលើកដីលុបអស់ទៅ គេយកអាថ្មនឹងចេញទៀត ។

ធានី :	គេគាស់ថ្មនឹងចេញទៀត?

សុទី :	មិនដឹងថាគេគាស់ចេញ មិនដឹងថាគេលុបថ្មនឹងក៏មិនដឹង គ្រាន់គ្មានបានដើរទៅណាយើងនៅ តែនឹង ដើរខ្វាចតែគេយកទៅវ៉ៃចោល ។

ធានី :	កាលពេលពូទៅដំបូង ត្រពាំងថ្មនឹងគ្រាន់វាជារាបស្មើ មិនទាន់មានទំនប់ មានអីទេ ឬក៏មានគេចាក់ហើយតែវាតូច?

សុទី :	មានតែ ខ្ញុំទៅធ្វើខាងក្រោយទេ គេហៅចល័តតំបន់គេធ្វើមុន ។

ធានី :	ចឹងកាលពេលពូទៅនៅឆ្នាំ៧០ប៉ុន្មាន?

សុទី :	ខ្ញុំ៧៦ ។

ធានី :	៧៦ពូទៅធ្វើត្រពាំងថ្ម?

សុទី :	ហ្នឹង ។

ធានី :	ចឹងបានន័យថាត្រពាំងថ្មនឹងមានតាំងពីមុននឹងមានគេធ្វើមុននឹងទៀត ទើបតែពូទៅក្រោយ?

សុទី :	ហ៎! គេទើបនឹងធ្វើសម័យយើងនេះ សម័យឆ្នាំ៧៥ ខាស់ខាងចល័តតំបន់គេធ្វើមុន ។

ធានី :	មុនតិចតួច ប៉ុនធ្វើឆ្នាំនឹងដដែល?

សុទី :	ហ្នឹងហើយ គេចាប់ធ្វើពីឆ្នាំ៧៥ មុន កាលនោះគ្រឿងចក្រនៅមានដែលយើងប្រមូលបានទៅ គេយកទៅធ្វើ ។

ធានី :	គេធ្វើយ៉ាងមេ៉ច គ្រឿងចក្រនៅមានដែលពូបានឃើញ?

សុទី :	ទេ! ឃើញគេ ដែលយើងវែកដីបាន អាឡូគេកិន មានអាឡូកិនបើកកិនកន្លែងកែងអាង ។

ធានី :	ពេលយើងទៅធ្វើនៅនឹង ពូនៅត្រពាំងថ្មនឹង គេឲ្យលើកដី ម៉ាថ្ងៃប៉ុន្មានម៉ែត្រគីប ឬយ៉ាងមេ៉ចដែរ គេឲ្យធ្វើការ?

សុទី :	ម៉ាថ្ងៃ៣ម៉ែត្រគីប ។

ធានី :	សម្រាប់ពូជាយុវជន?

សុទី :	ជាយុវជន ។

ធានី :	ជាយុវជន គឺ៣ម៉ែត្រគីប?

សុទី ៖ បាទ!

ធានី ៖ ចឹងកាលពូនៅកងកម្លាំងទី១ ឬទី២?

សុទី ៖ នៅកម្លាំងទី២ ។

ធានី ៖ កម្លាំងទី២នឹង ជាអ្នកណាដែលអាចចូលកម្លាំងទី២?

សុទី ៖ កម្លាំងទី២ កម្លាំងដែលទៅតាម ទៅពីភូមិគេហៅកម្លាំងទី២ អាកម្លាំងទី១គេហៅកម្លាំងចល័តតំបន់ អាកម្លាំងដាច់ខាតគេ ។ យើងគ្រាន់តែទៅ ។

ធានី ៖ ចឹងកម្លាំងនឹង កម្លាំងយុវជនតាមភូមិក៏គេហៅកងចល័តទី២?

សុទី ៖ ហ្នឹងហើយ ។

ធានី ៖ ដល់ពេលចល័តតំបន់នឹង?

សុទី ៖ កម្លាំងទី១ ។

ធានី ៖ ចល័តតំបន់នឹងយកអ្នកម៉េចវិញ បើតាមភូមិដូចតែគ្នានឹង?

សុទី ៖ តាមភូមិដូចតែគ្នា គ្រាន់តែគេថាគេនៅនោះ គេតំបន់អ្នកមករើសយក ។

ធានី ៖ ម៉ាថ្ងៃ៣ម៉ែត្រគីប សម្រាប់ពូយ៉ាងម៉េចដែរ ដូចថាពេល?

សុទី ៖ បេះតែស៊ូ បេះតែរួចឲ្យគេ បើថាមិនរួចត្រូវដឹបផគេប៉ុននោះឯង ។

ធានី ៖ អាចមានអ្នកខ្លះ៤ម៉ែត្រ ៥ម៉ែត្រមានទេ?

សុទី ៖ ទេ! មិនមាន ។ ទេ! ពួកកម្លាំងទី១ពុតែ៤ម៉ែត្រ ៥ម៉ែត្រ គេផ្សេងប្រឡងប្រណាំងគេម៉េច ពុគេនិយាយដែរតើ ។

ធានី ៖ ប៉ុន្តែមិនអាចមានដល់៦ម៉ែត្រ?

សុទី ៖ ដូចមិនមានទេ ។

ធានី ៖ ជាទូទៅនៅកម្លាំងទី២ គឺ៣ម៉ែត្រ?

សុទី ៖ ហ្នឹងហើយ៣ម៉ែត្រ ។

ធានី ៖ តែពេលពូធ្វើៗជាកុមារដែរ ឬក៏?

សុទី ៖ អត់ទេ ខ្ញុំធ្វើផ្សេង ។

ធានី ៖ យុវជនៗ?

សុទី ៖ ហ្នឹងហើយយុវជន គ្នាឯង ។

ធានី ៖ យុវជនទាំងអស់ស្របាលៗគ្នានឹង?

សុទី ៖ បាទ!

ធានី : ចុះកុមារគេធ្វើប៉ុន្មាន?

សុទី : កុមារកាលដែលពេលនោះដូចមិនឃើញមានទៅទេ ។

ធានី : ជំទង់មិនមែនក្មេងតូចៗពេកទេ អាយុ១៦?

សុទី : អត់មានទេ ទៅអាងត្រពាំងថ្មដូចអត់មានកុមារ មានជំទង់ មានតែយុវជនដែលទៅ ។

ធានី : ជាទូទៅមានយុវជន ហើយនឹងកម្លាំង?

សុទី : កម្លាំងដាច់ខាតម៉េចទេ មិនសូវដឹងភាសាគេ ។

ធានី : ចឹងពូធ្វើការកម្លាំង៣ម៉ែត្រគីប គេលើកយ៉ាងម៉េច ហើយយកទៅចាក់យ៉ាងម៉េច?

សុទី : រែកពីមាត់អន្លង់ឡើងទៅលើទំនប់ រែកឡើង ។

ធានី : ទំនប់នឹងកំពស់ប៉ុន្មាន លើកឡើង?

សុទី : ទេ! មុនចាក់លើដីស្មើ ចាក់ឡើងបានកំពស់ម៉ាម៉ែត្រ២ម៉ែត្រទៅណា ។ កាលដែលខ្ញុំនៅធ្វើ នោះក៏ធ្វើមិនបានយូរមិនបានរួច គេដកមកវិញ ។ ចប់គេហៅប្រមូលមកវិញ គេឲ្យមកនៅ ធ្វើស្រែប្រាំងនៅភ្នំលាភ មិនបានធ្វើចប់ទេ ។

ធានី : ចឹងពូធ្វើបានប៉ុន្មានខែ បានទៅត្រពាំងថ្ម?

សុទី : ធ្វើបានប៉ុន្មានទេ ៥-៦ខែអត់ចាំ ។

ធានី : ចឹង៥-៦ខែនឹង ពេលចូលខែវស្សា បានពូត្រឡប់មកវិញ?

សុទី : បាទ!

ធានី : ចឹងពូនៅ៧៦ ខែប្រាំង ត្រឡប់មកធ្វើអីទេ ធ្វើស្រែនៅភ្នំលាភ?

សុទី : នៅភ្នំលាភធ្វើស្រែប្រាំង អូរលាភព្រែកជីកនឹង ។

ធានី : ធ្វើស្រែប្រាំង ស្រែវស្សា?

សុទី : ស្រែប្រាំង ។

ធានី : មើលបើដើមឆ្នាំ៧៦ ពូមកធ្វើនៅត្រពាំងថ្ម៥-៦ខែ វាអាចខែប្រាំង ជិតចូលខែវស្សា ហើយ?

សុទី : ទាល់តែសម័យនោះវស្សាដូចប្រាំងៗដូចវស្សា បើថាខែវស្សាចេះនាំគ្នាបាច់បូមទឹកចេញ ។

ធានី : បើខែប្រាំងបូមទឹកចូលវិញ?

សុទី : នោះហើយ ។

ធានី : ចឹងជាទូទៅ គេធ្វើស្រូវប៉ុន្មានដងក្នុងម៉ាឆ្នាំ ដល់ពេលពូធ្វើ?

សុទី : ធ្វើនៅនោះ ធ្វើបាន២ដងម៉ាឆ្នាំ ។

ធានី ៖ ហើយមានអ្នករែកទំនប់ផ្សេងទៀត ឬក៏ធ្វើស្រែតែ២ដង?

សុទី ៖ អត់ទេ ពួកខ្ញុំដែលចេញពីនោះវិញ មកនៅធ្វើតែស្រែ ។

ធានី ៖ កាលពេលពូធ្វើនៅត្រពាំងថ្មនឹង អ្នកណាអ្នកគ្រប់គ្រង?

សុទី ៖ កាលធ្វើត្រពាំងថ្មឈ្មោះ ពូថន អ្នកគ្រប់គ្រង ។

ធានី ៖ គ្រប់គ្រងក្រុមពូ?

សុទី ៖ បាទ! ប៉ុនវាប់ហើយ ។

ធានី ៖ កងពូកាលនោះមានប៉ុន្មាននាក់?

សុទី ៖ អូ! អត់បានដឹងទេ អត់បានចាំទេ ។

ធានី ៖ ច្រើនទេ ១០០-២០០ គេហៅកងអីគេ?

សុទី ៖ បាទ! ម៉ាឃុំ ។

ធានី ៖ ម៉ាឃុំ?

សុទី ៖ ហ្នឹងហើយម៉ាឃុំព្រះនេត្រព្រះនៅលើតាផន គេជាអ្នកក្តាប់ ។

ធានី ៖ ចុះក្រៅពីតាផន មានអ្នកណាគេលើតាផននឹងទៀត?

សុទី ៖ លើតាផនដឹងអ្នកណាអី ។

ធានី ៖ អត់ចាំ?

សុទី ៖ អឺ! លើតាផន មានអ្នកគេនៅតំបន់នោះ គេនៅ ។

ធានី ៖ ឈ្មោះអី?

សុទី ៖ ដឹងឈ្មោះអី តំបន់គេអ្នកគ្រប់គ្រងអាង អត់ស្គាល់ ។

ធានី ៖ ចុះតាវ៉ាល់?

សុទី ៖ តាវ៉ាល់នឹង គាត់ខាងទាហាន ។

ធានី ៖ ចឹងពូធ្លាប់ស្គាល់ឃើញគាត់ដែរ?

សុទី ៖ ឃើញ តាវ៉ាល់ធ្លាប់ឃើញ ។

ធានី ៖ ចឹងគាត់មិនមែនខាងអាងនឹងទេ គាត់ខាងទាហាន?

សុទី ៖ ដឹងថាគាត់គ្រប់គ្រងទំនប់នោះផងក៏មិនដឹង ដឹងទំនប់នោះ ទំនប់ម៉ាតំបន់៥ហើយ អាងនោះ ។ ដឹងថាអាងត្រពាំងថ្មនោះប្រជាជនទៅម៉ាខេត្ត ម៉ាតំបន់៥ ទៅពីស្វាយ ថ្មពួក ស្វាយចេក ។

ធានី ៖ ចឹងទំនប់នឹងធំ?

សុទី ៖ អាងនឹងធំណាស់ ។

ធានី ៖ ហើយមានមនុស្សប៉ុន្មាននាក់?

សុទី ៖ ៤គីឡូ៤ជ្រុង ៥គីឡូ៤ជ្រុង ។ ដឹងប៉ុន្មានធំណាស់អាង ។

ធានី ៖ ព្រោះចេះពូធម្មតា កាលពេលធ្វើនឹងដូចថាវ៉ាវ៉ាល ចឹងយើងអាចវាស់បាន ដល់ឥឡូវទឹកល្ហាចល្ហឹម ខ្ញុំអត់ដឹងច្បាស់ ។ ដោយសារពូធ្លាប់ទៅធ្វើចឹង ពូអាចដឹងច្បាស់ជាងខ្ញុំ ។

សុទី ៖ ម៉ាឃុំព្រះនេត្រព្រះនេះគេឲ្យប៉ុន្មានម៉ែត្រ គេចែកម៉ែត្រគ្នា មិនចាំ ចែកម៉ែត្រគ្នារែកធ្វើទំនប់ ។

ធានី ៖ ចុះពូធ្វើ៣ម៉ែត្រគីបក្នុងម៉ាថ្ងៃចឹង អាចៗរួច?

សុទី ៖ រួចបាន រែកបាន ។

ធានី ៖ ហត់ខ្លាំង ឬក៏អីយ៉ាងម៉េចទេ ដូចថាពេលខ្លះត្រូវតដល់យប់ទៀតអត់ ងើបពីព្រលប់ គេពីយប់?

សុទី ៖ ខ្ញុំដូច យប់អត់មាន យប់ដឹងថាពស្រាបទេ ពេលដែលយើងរែករួចពីថ្ងៃទៅ ល្ងាចបាយមកក៏យើងតំរាបម៉ាភ្លែត តំរាបដី ។

ធានី ៖ ចុះពូដែលឃើញអ្នកផ្សេង ដែលធ្វើការដល់យប់ ដូចថាយើងធ្វើអត់ហើយរបស់គេ ហើយយើងត្រូវធ្វើដល់យប់?

សុទី ៖ មិនបានចាប់អារម្មណ៍ ដឹងថាធ្វើដឹងថាហើយឲ្យគេក្នុងម៉ាថ្ងៃ៣ម៉ែត្រគីបដឹងតែហើយឲ្យគេ ។

ធានី ៖ មានអ្នកណាធ្វើហើយមុន ឬក៏ក្រហើយនៅក្នុងកង?

សុទី ៖ ទេ! ជួយគ្នា ។

ធានី ៖ ជួយគ្នាធ្វើទាំងអស់?

សុទី ៖ ហ្នឹងហើយជួយគ្នាលើករួចទាំងអស់គ្នា ។

ធានី ៖ ចុះដូចអ្នកថ្មីអី គេមកធ្វើជាមួយពូដែរ ឬក៏អត់?

សុទី ៖ ធ្វើៗជាមួយដែរ ។

ធានី ៖ គាត់ធ្វើយ៉ាងម៉េច ធ្វើម៉េចបានហើយ?

សុទី ៖ ទេ! ខ្លះទៅធ្វើបាន ខ្លះទៅអត់បានទេ ក៏ជួយគ្នា ពួកអ្នកមកថ្មីច្រើនតែស្គមៗ ប៉ុនអត់ដូចអ្នកនៅមូលដ្ឋាននេះទេ ។

ធានី ៖ ដល់ចឹង ពួកគាត់ធ្វើអត់បានមានអ្នកណាគេដាក់ទោសគាត់អត់ បើសិនជាធ្វើអត់ហើយ ដូចពូថាស្លុមៗ?

សុទី ៖ អូ! អារឿងដាក់នោះអត់ដឹងទេ ដាក់ហើយដឹងថាមិនដឹង គេដាក់មានឲ្យខ្ញុំដឹង។

ធានី ៖ តែពូដឹងថាមានគេដាក់ទោស?

សុទី ៖ ដឹង មាន។

ធានី ៖ តែមានអ្នកបាត់ខ្លួន?

សុទី ៖ ហ្នឹងហើយបាត់ខ្លួននោះឯង ធ្វើៗក៏ឃើញគេអ្នកចាប់មើលច្រើនដង បាត់ខ្លួនតែម្តង។

ធានី ៖ អ្នកថ្មីនឹង?

សុទី ៖ ហ្នឹងហើយ អ្នកថ្មី។

ធានី ៖ ហើយយ៉ាងម៉េចទៅ ដូចថា អត់ដឹងបាត់ខ្លួនដោយសារអី?

សុទី ៖ ហ្នឹងហើយអត់ដឹងទេ។

ធានី ៖ គ្រាន់ពូដឹងព្យាយាមធ្វើការខ្លួនឯង?

សុទី ៖ នោះហើយ ដឹងធ្វើម៉េច ដោះស្រាយដោយខ្លួនឯងទាល់តែរួច។

ធានី ៖ ចុះមានដូចថាពួកគាត់ អ្នកថ្មីអស់នឹង គាត់មានដែលប្រាប់ពូធ្វើនេះចឹង ដែលធ្លាប់មានទេ?

សុទី ៖ ទេ! មិនដែលមានប្រាប់ទេ។

ធានី ៖ ចុះអ្នកដែលធ្វើការថ្មីអស់នឹង ភាគច្រើន គាត់បាត់ខ្លួនច្រើន ឬមួយក៏យ៉ាងម៉េចដូចថាគាត់មកម្តង គាត់បាត់ទៅខ្លះ មួយក៏នៅធ្វើរហូតដល់ចប់?

សុទី ៖ ទេ! ច្រើនបាត់ជួនកាលច្រើនបាត់អាអ្នកធាត់ក៏មានដែរ។ រត់ពីនេះទៅ ខ្លះក៏រត់ទៅ។

ធានី ៖ គេប្រាប់ពូថារត់?

សុទី ៖ ទេ! មិនមានប្រាប់ទេ គ្រាន់ថាខ្លះទៅគេខ្សឹបខ្សៀវគ្នាទៅថារត់ថាអីណា។

ធានី ៖ តែមានរត់ទៅ គេចាប់មកវិញ ឲ្យមកធ្វើការវិញទេ?

សុទី ៖ អឺ! បើចាប់មកវិញ គេដែលឲ្យមកកន្លែងដើមវិញទេ ចាប់យកទៅណា។

ធានី ៖ ប៉ុន្តែធ្លាប់មានទេ?

សុទី ៖ ធ្លាប់មានៗពូ។

ធានី ៖ គេប្រកាសប្រាប់ ឬក៏យើងខ្សឹបខ្សៀវគ្នា?

សុទី ៖ ទេ! អត់ទេ ខ្សឹបខ្សៀវគ្នា។

ធានី ៖ ស្គាល់ឈ្មោះគាត់?

សុទី ៖ អត់ចាំទេ ។

ធានី ៖ ចុះដូចថាពូអ្នករៀន អ្នកអីចឹង គេអត់សួរនាំប្រវត្តិទេ?

សុទី ៖ ទេ! មុនដំបូងសួរដែរតើ ប្រាប់គេថាអ្នកនៅរៀន ដល់ក្រោយៗមកគេអត់សូវសួរអី ដល់យើងធ្វើការឲ្យគេល្អទៅ យើងមិនដែលតវ៉ាមិនដែលអី ចេះតែនៅៗនឹងគេ ។

ធានី ៖ ពេលធ្វើការចឹង មិញពូថានៅរែកទំនប់ៗ សម្រាប់ជួបពួកម៉ាក់ចាស់អ្នកធ្វើ?

សុទី ៖ ហ្នឹងហើយ អ្នករៀន ។

ធានី ៖ អ្នករៀនជាមួយគ្នា គាត់ដឹកអីឲ្យ គេអត់ថាអី?

សុទី ៖ ទេ! មានថាអី ។

ធានី ៖ ពូធ្វើការនៅនឹងប៉ុន្មានខែ?

សុទី ៖ គេដើរមើលការដ្ឋានយើង ដើរមកមើលឃើញល្ងាចឡើងគេហៅឲ្យទៅយកត្រីងៀត ទៅកន្លែងគេឲ្យត្រីងៀតអី ។

ធានី ៖ គាត់ងារធ្វើអីគេ?

សុទី ៖ ខ្ញុំមិនបានហ៊ានសួរគេទេ ដឹងថាគេធ្វើអី គេថាគេអ្នកប្រមូលស្បៀង ឃើញគេដឹកត្រីងៀតយកមកឲ្យអ្នកចល័តស៊ី ។

ធានី ៖ តែពូដែលបានហូបអស់នឹង?

សុទី ៖ ហូបគេឲ្យម្ដង ។

ធានី ៖ មិនមែនទេ ចង់និយាយថាពេលដែលពូនៅធ្វើការកងចល័តនឹង តើពូបានហូបអ្វីដែលមិត្តភ័ក្ដរបស់ពូឲ្យហូបនឹងទេ? មិញពូប្រាប់ថា គាត់នឹងអ្នកកាន់ស្បៀងឲ្យកងចល័ត មែនទេ?

សុទី ៖ អឺ!

ធានី ៖ ចឹងចង់សួរពូថា ពេលដែលគេឲ្យពូហូបនៅកងចល័តនឹង តើមានគេឲ្យដូចថាមានជាត្រីងៀតជាស្ករ គាត់បានឲ្យដែលបានហូបទេ?

សុទី ៖ បានហូបម្ដង ដែលរបបហូបទាំងអស់នោះ ។

ធានី ៖ ចា៎!ចង់និយាយថារបបហូបទាំងអស់គ្នា មិនមែនចង់និយាយថាជាបុគ្គលទេ ប៉ុន្តែចង់សួរពូថាគាត់កាន់ឃ្លាំង ចឹងគាត់មិនមានរបស់អស់នឹង តើនៅពេលដែលហូបជុំគ្នានៅកង?

សុទី ៖ ហូបទាំងអស់គ្នា ។

ធានី ៖ បានហូបរបស់ដែលគាត់ឲ្យពូអត់ ដូចឲ្យត្រីងៀតអីចឹង?

សុទី ៖ ហ្នឹងហើយបានៗ ។

ផានី ៖ ធ្លាប់បានហូបចល័តទាំងអស់គ្នា?

សុទី ៖ បាន ។

ផានី ៖ បានហូបច្រើនដង បានហូបបាយ ក៏ហូបបបរ?

សុទី ៖ ដែលនៅនោះហូបបាយ ។

ផានី ៖ ហូបបាយកងចល័តនឹង?

សុទី ៖ បាទ!

ផានី ៖ ហូបបាយហូបឆ្អែត?

សុទី ៖ ហូបឆ្អែតដែលមានកម្លាំងរែកដីកើតដែរ ទាល់ម្ហូបអត់មានម្ហូបដើររកខ្លួនឯង ។

ផានី ៖ ហូបខ្លួនឯង ដាំបាយឲ្យហូប ហើយកងចល័តរបស់ពូបានហូបទាំងអស់គ្នារហូតដល់បានពូដូរទៅកន្លែងផ្សេងវិញ ។ ចុះពេលដែលពូរស់នៅនឹង មានការលំបាកអីដែរអត់?

សុទី ៖ លំបាកៗ ទាល់យើងអ្នកស្រែស្រេច ទឹកដីយើងធ្លាប់រស់នៅ មិនសូវមានជម្ងឺឈឺថ្កាត់អីដូចអ្នកមកថ្មី ។

ផានី ៖ អ្នកមកថ្មីឈឺថ្កាត់ជម្ងឺអីគេ?

សុទី ៖ ច្រើនតែរាគរូស ។

ផានី ៖ ម៉េចចឹង?

សុទី ៖ បើឃើញតែស្គមៗស្លាប់ ។

ផានី ៖ ម៉េចបានរាគរូសចឹង?

សុទី ៖ ហើម ។

ផានី ៖ ហូបអត់គ្រប់?

សុទី ៖ ដំណើរបែបហូបមិនគ្រប់ ។

ផានី ៖ តែអ្នកថ្មី អ្នកចាស់ហូបបាយដុំគ្នា?

សុទី ៖ ដុំគ្នា ។

ផានី ៖ ហូបដូចតែគ្នា?

សុទី ៖ ហូបដូចតែគ្នា ។

ផានី ៖ ម៉េចក៏អ្នកថ្មីទៅជាឈឺ អ្នកចាស់អត់ឈឺ?

សុទី ៖ មិនដឹងម៉េច ហូបបាយដុំតែគ្នា ។

ផានី ៖ ចុះពូដូចថាអ្នកថ្មីនឹង ពេលដែលគាត់ឈឺ មានពេទ្យមានអីគេមើល ឬក៏យ៉ាងម៉េច?

សុទី ៖ ពេទ្យមាន ពេទ្យអាចមន៍ទន្សាយ ។

ធានី ៖ ឲ្យតែឈឺអីក៏ប្រើអានឹងដែរ?

សុទី ៖ ហ្នឹង ។

ធានី ៖ តែពេលយើងឈឺ អាចសម្រាកបានទេ?

សុទី ៖ ឈឺសម្រាកបានតើ ។

ធានី ៖ បានយូរទេ?

សុទី ៖ ដឹងយូរមិនយូរ មិនបាននៅកន្លែង ។

ធានី ៖ ចង់និយាយថា ពេលដែលពូនៅកន្លែងនឹង?

សុទី ៖ ហេ៎! អានោះឈឺក្បាលវិលមុខតិចតួច អានោះបានម៉ាពេលៗ តែយូរគេហៅយកទៅកន្លែងពេទ្យ គេឲ្យប្រធានកងយកទៅកន្លែងពេទ្យ ។

ធានី ៖ កាលពេលពូធ្វើនៅទំនប់នឹង មនុស្សច្រើន?

សុទី ៖ ច្រើន មនុស្សច្រើន ។

ធានី ៖ ប៉ុន្មាននាក់?

សុទី ៖ អឺ! រាប់ម៉េចបាន ថាម៉ាតំបន់ មនុស្សម៉ាតំបន់៥ ។

ធានី ៖ ប៉ុន្មានប៉ុននឹង?

សុទី ៖ មិនដឹងប៉ុន្មានម៉ឺននាក់ទេ ។

ធានី ៖ ម៉ាឃុំពូកាលនឹងទៅប៉ុន្មាននាក់?

សុទី ៖ ខ្ញុំមិនដឹងទេ ។

ធានី ៖ ច្រើនពេក?

សុទី ៖ ខ្ញុំអ្នកនេះភូមិ ចំណែកមួយនៃភូមិ ។

ធានី ៖ កាលពេលពូទៅតំបន់ចឹង ដឹងអ្នកណាគេអ្នករៀបចំគ្រប់គ្រងនៅអាងត្រពាំងថ្មនឹងទេ ឬក៏អ្នកណាគេផ្តួចផ្តើមឲ្យបង្កើតមានអាងមានអី?

សុទី ៖ អត់ មិនដឹងទេ ។

ធានី ៖ អត់ដឹងថាអ្នកណាគេគ្រប់គ្រងនៅនឹងទេ?

សុទី ៖ អត់ ។

ធានី ៖ មិញពូថាស្គាល់តាវ៉ាល់ ស្គាល់ថាគាត់ជាយោធា អត់ដឹងថាគាត់ជាអ្នកណាទេ?

សុទី ៖ ហ្នឹងហើយ ស្គាល់យោធា ។

ធានី ៖ ហេតុអីបានពូដឹងថាគាត់យោធា?

សុទី ៖ ចុះឃើញគាត់ពាក់ខោអាវ ស្ពាយកាំភ្លើងដើរមើលតាមទំនប់ គាត់ដើរទៅជួបឃុំគាត់ អ៊ឹជន ។

ធានី ៖ អ៊ឹជន ដែលអ្នកដឹងនាំពូ?

សុទី ៖ បាទ!

ធានី ៖ បន្ទាប់ពីក្រោយធ្វើអានឹងហើយ ពូថាត្រឡប់មកធ្វើស្រែនៅភ្នំលាភ?

សុទី ៖ ភ្នំលាភ ។

ធានី ៖ ហើយធ្វើស្រែនៅនឹងរហូត ឬមួយក៏មានទៅណាទៀតទេ?

សុទី ៖ ធ្វើស្រែនៅរួចនៅធ្វើស្រែនឹងយូរដែរ ៧៦ ៧៧ ដល់៧៨បានមកផ្ទះវិញ ។

ធានី ៖ ធ្វើស្រែនឹងធ្វើអីគេ ស្ទូងស្រូវ?

សុទី ៖ ភ្ជួរដីឲ្យគេ ។

ធានី ៖ កងភ្ជួរ?

សុទី ៖ ហ្នឹងហើយកងភ្ជួរ ។

ធានី ៖ ចឹងពេលពូធ្វើនៅនឹងមានធ្លាប់ជួនរឿងអីប្លែកៗ ដូចធ្លាប់មានអីដែលថា?

សុទី ៖ អូ! មិនមានជួបអីទេ តែព្រលឹមឡើងមើលតែគោម៉ាទឹមឲ្យតែធាត់មានកម្លាំងអូសនង្គ័ល ។ គេប្រគល់ឲ្យគោម៉ាទឹម រទេះមួយ នង្គ័លមួយក៏ ។

ធានី ៖ តែពូម្នាក់ឯងទេ ធ្វើស្រែ ឬមានអ្នកផ្សេងទៀត?

សុទី ៖ កាលនោះម៉ាសហករណ៍ទៅ៣នាក់ ។

ធានី ៖ ឈ្មោះអីខ្លះទៅ?

សុទី ៖ ឈ្មោះ យឿត នោះមួយ ហ៎!តែ២នាក់តើ ២នាក់យឿតនោះ គ្មាន៣ណា ។

ធានី ៖ យឿត ហើយនឹងពូ?

សុទី ៖ នោះហើយ ។

ធានី ៖ តែ២នាក់នឹងកងភ្ជួរ?

សុទី ៖ ទេ! ទៅរួមគ្នា ក្នុងម៉ាភូមិគេយកទៅ២ ម៉ាភូមិព្រះនេត្រព្រះនេះ ខ្ញុំនៅភូមិជើងវត្តនេះគេយកទៅ២ ភូមិប៉ោយក្លៀក៏២ទៅ ១៣ភូមិគេយក ។

ធានី ៖ ប៉ុន្មាននាក់ទៅម៉ាកងភ្ជួររបស់ពូ?

សុទី ៖ ១៣ភូមិ ម៉ាភូមិ២នាក់ គុណ១៣ ២៦នាក់ ។

ធានី ៖ ចឹង២៦នាក់ទៅកងភ្លួរ ។ អ្នកណាគេអ្នកដឹកនាំទៅ?

សុទី ៖ កាលនោះប្រធាននៅនោះ ដឹងអ្នកណាទេ ប្រធានភ្លួរនោះ ក្លេចអស់ទៅហើយ ឆាប់អស់ ប្រធានភ្លួរៗកាលនោះគេវ័យកណ្តាល គេអាយុច្រើនមានគ្រួសារ ។

ធានី ៖ គាត់មកពីខាងណាវិញ?

សុទី ៖ ទេ! អ្នកនៅក្នុងភូមិគ្នាឯង អ្នកនៅក្នុងឃុំ ប្រធានភ្លួរនោះ ។

ធានី ៖ ឈ្មោះអីគេ?

សុទី ៖ រកនឹកមិនឃើញ ។

ធានី ៖ នៅធ្វើរហូតមកដល់ឆ្នាំ៧៨ពូថាត្រឡប់មកផ្ទះវិញ ត្រឡប់មកភូមិយើងវិញ?

សុទី ៖ បាទ!

ធានី ៖ ពេលនឹងវៀតណាមចូលនៅ?

សុទី ៖ នៅទាល់តែ៧៩ បានបែក ។

ធានី ៖ ចុះម៉េចបានពូត្រឡប់មកវិញ គេឲ្យមក?

សុទី ៖ គេឲ្យមក ។

ធានី ៖ កាលនឹងពូអត់ទាន់រៀបគ្រួសារទេ?

សុទី ៖ នៅ ។

ធានី ៖ មានហើយ តែពូអត់ព្រម?

សុទី ៖ នៅអត់ទាន់មាន ។

ធានី ៖ គេអត់ទាន់រៀបចំឲ្យយើងមាន?

សុទី ៖ ហ្នឹង ។

ធានី ៖ ពេលមកដល់ផ្ទះ៧៨ ធ្វើអីគេ?

សុទី ៖ ៧៨មកកវិញ ក៏នៅធ្វើស្រែដែរ ធ្វើស្រែជុំអ្នកវ័យកណ្តាល ។

ធានី ៖ ជាមួយអ្នកវ័យកណ្តាល?

សុទី ៖ ហ្នឹងហើយ ។

ធានី ៖ ចឹងកងភ្លួរពូ ភាគច្រើនសុទ្ធតែវ័យកណ្តាលទេ មានពូក្មេង?

សុទី ៖ បាទ! ក្មេង ។

ធានី ៖ បន្ទាប់មកម៉េចទៀតពូ ពេល៧៨ចូលភ្លួរហើយ វៀតណាមចូលវិញ ពូនៅនឹងដដែល?

សុទី ៖ នៅនឹងដដែល ។

ធានី ៖ ហើយពូចាប់ផ្ដើមធ្វើអី?

សុទី ៖ ពូថាបាញ់គ្នានោះទៅ ក៏នាំគ្នារត់ឡើងទៅលើអស់រលីង គេអ្នកនៅជិតឱតខ្មែរក្រហមគេទៅតាមទៅ យើងអ្នកមិនមែនខ្មែរក្រហម យើងនៅ។

ធានី ៖ ចុះពេលនឹងខ្លះដូចថា ទ័ពវៀតណាមទៅបាត់ចឹង ដែលមានខ្មែរក្រហមឡុកចូលភូមិយើងទេ?

សុទី ៖ ទេ! ដូចមិនមានទេ មានយើងបន្ទាប់ពីវៀតណាមចូលមកដល់ វៀតណាមរៀបចំមូលដ្ឋានរៀបចំកម្លាំងយាមកាមអីទៅ។

ធានី ៖ តែមានខ្មែរក្រហមមកប្រទុសប្រទះអីនៅភូមិយើង?

សុទី ៖ អត់មានទេ គ្រាន់តែឡានបរចេញតាមថ្នល់ជាតិនាំគ្នារត់អស់។

ធានី ៖ កាលនៅភូមិយើងមានសេនាជន មានអីការពារភូមិ?

សុទី ៖ ទេ! វៀតណាមនេះមកក៏រៀបចំសេនាជន រៀបចំអីហើយ។

ធានី ៖ គ្រាន់ការពារភូមិ?

សុទី ៖ បាទ! ការពារភូមិ។

ធានី ៖ ការពេលនឹងពូដូចមិនសូវមានអីហូបចុក ដល់ពេលវៀតណាមចូលមកដល់ចឹង តើមានហូបចុកអីគ្រប់គ្រាន់?

សុទី ៖ មាន ប្រូតស្រែស្រូវ ពេលដែលវារត់ទៅ ស្រូវអត់ទាន់បានប្រូតស្រូវណា នៅអ្នកស្រុកនាំគ្នាទៅប្រូត យកទៅទុកស៊ី។

ធានី ៖ អ្នកណាប្រូតបានច្រើន អ្នកនឹងបានហូបច្រើន?

សុទី ៖ បាទ!

ធានី ៖ ដល់ពេលក្រោយមកទៀត ដូចថាដីអីៗគេបែងចែកតាមសហករណ៍ ឬបែងចែកតាមភូមិប្រជាជនប៉ុន្មាននាក់គេយកប៉ុននឹង ឬក៏យើងចាប់បានប៉ុន្មាន យកប៉ុននឹង?

សុទី ៖ អត់ទេ គេចែកគ្រប់។

ធានី ៖ គេចែក គេអត់ឲ្យយើងយកស្រេចចិត្តទេ?

សុទី ៖ នោះហើយ អ្នកដែលអត់ក៏គេឲ្យបានទាំងអស់គ្នា គ្រប់គ្នា។

ធានី ៖ ចុះមានអ្នកដែលជាខ្មែរក្រហម គាត់ធ្វើការនៅភូមិនេះ ហើយដល់ពេលខ្មែរក្រហមទៅគាត់ អត់រត់ទៅតាម?

សុទី ៖ មានអ្នកនៅនឹងភូមិនេះ និរតី។

ធានី ៖ មានដែរ?

សុទី ៖ មានម្នាក់ ។

ធានី ៖ ឈ្មោះអីគេ?

សុទី ៖ អូ! ឈ្មោះអី ។

ធានី ៖ តែនៅភូមិយើងដែរ?

សុទី ៖ នៅភូមិនេះឯង ទាល់តែគាត់ទៅនៅនេះបាត់ នៅកូនដំរី ។

ធានី ៖ ឥឡូវគាត់ទៅនៅកូនដំរី?

សុទី ៖ នោះឯង និរតីម្នាក់ ។

ធានី ៖ អ្នកនិរតីដែលគាត់មកនៅហើយ ម៉េចបានគាត់ទៅនៅកូនដំរី?

សុទី ៖ គាត់យកប្ដីអ្នកមូលដ្ឋានទៅ ក៏គាត់ទៅនៅនេះទៅ ផ្ទះនៅនេះ ។

ធានី ៖ គាត់នៅទេ?

សុទី ៖ អត់នៅទេ ទៅនៅកូនដំរី ទៅរកត្រីរកអី ។

ធានី ៖ ចឹងពូមកដល់សព្វថ្ងៃនេះ ដូចថាពូមានធ្វើការងាររដ្ឋដែរ?

សុទី ៖ បាទ!

ធានី ៖ ចឹងពូធ្វើតាំងពីឆ្នាំណា ការងារ?

សុទី ៖ ការងាររដ្ឋតាំងពី៧៩នេះឯង បានក្របខ័ណ្ឌតាំងពីឆ្នាំ៨០ ៨១ ។

ធានី ៖ ពូធ្វើការផ្នែកអីគេ?

សុទី ៖ មុនដំបូងកសិកម្មស្រុក ដល់ក្រសួងរៀបចំដែនដីគេបង្កើតទៅ គេដកពីកសិកម្មទៅដាក់ក្រសួងរៀបចំដែនដី ។

ធានី ៖ ងារជាអីដែរ?

សុទី ៖ ប្រធានការិយាល័យ ។

ធានី ៖ រាល់ថ្ងៃពូប្រធានការិយាល័យស្រុក?

សុទី ៖ ប្រធានការិយាល័យ រៀបចំដែនដីនគរូបនីយកម្ម សំណង់ ភូមិបាលស្រុកព្រះនេត្រព្រះ ។

ធានី ៖ ពូដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

សុទី ៖ ឮតើ ។

ធានី ៖ តាមដានរាល់ថ្ងៃដែរ?

សុទី ៖ បានមើលតើ បានមើលរាល់តែខែ ។

ធានី ៖ បានមើលអីគេ?

សុទី ៖ ទេ! ទស្សនាវដ្ដីបានមើលរាល់តែខែ ។

ធានី ៖ គេកាត់ទោសអ្នកទាំងអស់នឹង ពូដឹងថាឌុចគេឲ្យកាត់ទោសប៉ុន្មានឆ្នាំៗ ?

សុទី ៖ ដឹងកាត់ទោសឌុច រួច ។

ធានី ៖ ដឹងកាត់ទោសរួចហើយ ពូបានមើលគេកាត់ទោសនឹង?

សុទី ៖ អត់បានមើល ។

ធានី ៖ តែដឹងថាមានគេកាត់ទោសហើយ?

សុទី ៖ បាទ! កាត់ទោសឌុចហើយ ។

ធានី ៖ ហើយ៤នាក់ទៀត អ្នកណាគេ?

សុទី ៖ អៀង សារី, ប្រពន្ធអៀង សារី, អីអ្នកណាទៀត ។

ធានី ៖ ខៀវ សំផន, នួន ជា ។

សុទី ៖ បាទ! ខៀវ សំផន, នួន ជា ។

ធានី ៖ ពូយល់ គិតថា គេបង្កើតតុលាការនឹងមានប្រយោជន៍អត់ ចិត្តពូ?

សុទី ៖ មានប្រយោជន៍នោះឯង កុំឲ្យគំរាមអ្នកក្រោយៗកុំឲ្យដូចប៉ុលពត ។

ធានី ៖ ជាលើកចុងក្រោយ ខ្ញុំអស់អីសួរពូ តើពូមានអីចង់សួរខ្ញុំវិញ ឬក៏មានអីចង់បន្ថែម?

សុទី ៖ អស់ហើយ អត់មានអីសួរ ។

ធានី ៖ អត់មានអីសួរ ចឹងអរគុណពូច្រើន ។

«ចប់»